ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់ចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក សំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ

*****

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ-បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកំណត់ចំណាយដោយឡែក សំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និង កីឡា

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣

សំរេច

មាត្រា ១.-

អនុក្រឹត្យនេះកំណត់ការចំណាយដោយឡែកសំរាប់ការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅកំរិតមធ្យមសិក្សាបឋមភូមិ ដែលប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា តែប៉ុណ្ណោះ ។

មាត្រា ២.-

ការចំណាយដោយឡែកនេះ ត្រូវអនុវត្តសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ រៀងរាល់ឆ្នាំ ចាប់ពី ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣ តទៅ ។

មាត្រា ៣.-

ប្រាក់ឧបត្ថម្ភផ្តល់ដល់សិស្សអាហារូបករណ៍ក្រោមកម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ជូនយ៉ាងច្រើន ១៨០.០០០៛ (មួយរយប៉ែតសិបពាន់រៀលគត់) ក្នុងមួយនាក់ ក្នុងឆ្នាំសិក្សានីមួយៗ ដែលមាន ១០ (ដប់)ខែ សំរាប់ការផ្គត់ផ្គង់សំភារៈសិក្សាជាមូលដ្ឋាន សំលៀកបំពាក់ឯកសណ្ឋាន និង មធ្យោបាយធ្វើដំណើរ ។

ការផ្តល់អាហារូបករណ៍ក្នុងឆ្នាំសិក្សានីមួយៗមានចំនួន ៣ (បី)លើក ស្របតាមឆ្នាំថវិកា ។

មាត្រា ៤.-

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវធ្វើសារាចរណែនាំ ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ ក្នុងការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ៥

-កាលប្បវត្តិ-ឯកសារ